ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ
លេខ បព ២៧/២០២៥ កបទ.សអ

សេចក្ដីប្រកាសព័ត៌មាន

# សម្ដេចធិបតីនាយករដ្ឋមន្ត្រី ហ៊ុន ម៉ាណែត បានជួបប្រជុំជាមួយ ឯកឧត្តមប្រធានាធិបតី ស៊ី ជីនពីង ក្នុងឱកាសកិច្ចប្រជុំកំពូល អង្គការសហប្រតិបត្តិការសៀងហៃបូក

នៅថ្ងៃទី៣០ ខែសីហា ឆ្នាំ២០២៥ **សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានជួបសម្ដែងការគួរសមជាមួយ **ឯកឧត្តម ស៊ី ជីនពីង ប្រធានាធិបតី** នៃសាធារណរដ្ឋប្រជាមានិតចិន ក្នុងឱកាស**សម្ដេចធិបតីនាយករដ្ឋមន្ត្រី** អញ្ជើញចូលរួមកិច្ចប្រជុំកំពូលនៃអង្គការសហប្រតិបត្តិការសៀងហៃបូក ចាប់ពីថ្ងៃទី៣១ ខែសីហា ដល់ថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០២៥ នៅទីក្រុងធានជីន សាធារណរដ្ឋប្រជាមានិតចិន។

ថ្នាក់ដឹកនាំទាំងពីរបានបញ្ជាក់សារជាថ្មីនូវចំណងមិត្តភាពដែកថែបដ៏យូរអង្វែងរវាងកម្ពុជា និងចិន ហើយបានពិភាក្សាស៊ីជម្រៅលើការពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការលើវិស័យសំខាន់ៗ ដែលជាផលប្រយោជន៍ទៅវិញទៅមកនៃប្រទេស និងប្រជាជនទាំងពីរ។ ភាគីទាំងពីរបានរំលឹកពីដំណើរទស្សនកិច្ចផ្លូវរដ្ឋជាប្រវត្តិសាស្ត្ររបស់ **ឯកឧត្តមប្រធានាធិបតី** មកកាន់ប្រទេសកម្ពុជា កាលពីខែមេសា ឆ្នាំ២០២៥ និងបានបញ្ជាក់ការប្ដេជ្ញាចិត្តរួមគ្នាក្នុងការអនុវត្តនូវកុងសង់ស៊ីសសំខាន់ៗដែលបានឯកភាពអំឡុងពេលដំណើរទស្សនកិច្ច និងការជំរុញចក្ខុវិស័យរួមគ្នានៃការកសាងសហគមន៍វាសនារួមកម្ពុជា-ចិន ក្នុងយុគសម័យថ្មី គ្រប់រដូវកាល ។

**ឯកឧត្តមប្រធានាធិបតី** បានបញ្ជាក់សារជាថ្មីនូវការគាំទ្រដ៏រឹងមាំរបស់ចិនសម្រាប់ការអភិវឌ្ឍការធ្វើទំនើបកម្ម និងសមាហរណកម្មក្នុងតំបន់របស់កម្ពុជា។ **ឯកឧត្តមប្រធានាធិបតី** បានគូសបញ្ជាក់អំពីការប្ដេជ្ញាចិត្តរបស់ប្រទេសចិន ក្នុងការបង្កើនកិច្ចសហប្រតិបត្តិការក្រោមក្របខណ្ឌទ្វេភាគីសំខាន់ៗរួមមានកិច្ចសហប្រតិបត្តិការត្បូងពេជ្រ "ច្រករបៀងមច្ឆា និងអង្ករ" និងច្រករបៀងឧស្សាហកម្ម និងបច្ចេកវិទ្យា។

**សម្ដេចធិបតីនាយករដ្ឋមន្ត្រី** បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះការរួមចំណែកដ៏យូរអង្វែងរបស់ប្រទេសចិនក្នុងការអភិវឌ្ឍសេដ្ឋកិច្ចសង្គមកម្ពុជា។ **សម្ដេចធិបតីនាយករដ្ឋមន្ត្រី** បានសង្កត់ធ្ងន់ពីសារៈសំខាន់នៃការពង្រីកបន្ថែមទៀតនូវពាណិជ្ជកម្ម និងការវិនិយោគទ្វេភាគី ការពង្រឹងខ្សែច្រវាក់ផ្គត់ផ្គង់ តាមរយៈការប្រើប្រាស់កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-ចិន។ ចំពោះការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ **សម្ដេចធិបតីនាយករដ្ឋមន្ត្រី** បានគូសបញ្ជាក់ពីសារៈសំខាន់ដ៏ធំធេងនៃការ

អាសយដ្ឋាន: លេខ ៣ វិថី សម្ដេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 216 122
ទូរសារ : (855) 23 216 141, 023 213 341
អ៊ីម៉ែល: mfaic@mfaic.gov.kh

បន្តគាំទ្ររបស់ប្រទេសចិន រួមមានគម្រោងគ្រប់គ្រងធនធានទឹកចំរុះហ្វូណនតេជោ និងការគ្រប់គ្រងធនធានទឹក។ **ឯកឧត្តមប្រធានាធិបតី** បានលើកទឹកចិត្តស្ថាប័នពាក់ព័ន្ធនៃប្រទេសទាំងពីរ ឱ្យចូលរួមសម្របសម្រួលយ៉ាងជិតស្និទ្ធ ដើម្បីធានាបាននូវការអនុវត្តនៃគម្រោងហេដ្ឋារចនាសម្ព័ន្ធដែលមានស្រាប់ឱ្យបានទាន់ពេលវេលា សំដៅផ្តល់អត្ថប្រយោជន៍ជាក់ស្តែងដល់ប្រជាជននៃប្រទេសទាំងពីរ។

ថ្នាក់ដឹកនាំទាំងពីរក៏បានពិភាក្សាអំពីកិច្ចសហប្រតិបត្តិការលើវិស័យការពារជាតិ និងសន្តិសុខ និងបានឯកភាពពង្រឹងកិច្ចសហប្រតិបត្តិការបន្ថែមទៀត ក្នុងការកសាងសមត្ថភាព និងកិច្ចសហប្រតិបត្តិការដើម្បីប្រយុទ្ធប្រឆាំងនឹងបទល្មើសបច្ចេកវិទ្យា រួមមានការឆបោកតាមអ៊ីនធឺណែត និងឧក្រិដ្ឋកម្មឆ្លងដែននានា។

ពាក់ព័ន្ធនឹងស្ថានការណ៍ព្រំដែនកម្ពុជា-ថៃ **ឯកឧត្តមប្រធានាធិបតី** បានបញ្ជាក់សាជាថ្មីនូវការគាំទ្ររបស់ប្រទេសចិនចំពោះកិច្ចព្រមព្រៀងបទឈប់បាញ់រវាងប្រទេសទាំងពីរ យន្តការសង្កេតអាស៊ានដែលដឹកនាំដោយម៉ាឡេស៊ី និងការបង្កើតក្រុមអ្នកសង្កេតការណ៍អាស៊ាន (AOT)។ **ឯកឧត្តមប្រធានាធិបតី**ក៏បានប្រកាសថា ប្រទេសចិននឹងផ្តល់ជំនួយមនុស្សធម៌ដល់កម្ពុជា ដើម្បីគាំទ្រដល់ការកសាងឡើងវិញ និងការស្តារជីវភាពសម្រាប់សហគមន៍ដែលរងផលប៉ះពាល់ដោយជម្លោះប្រដាប់អាវុធនាពេលថ្មីៗនេះ។

ជាការឆ្លើយតប **សម្តេចធិបតីនាយករដ្ឋមន្ត្រី** បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះតួនាទីដ៏សំខាន់ និងប្រកបដោយការស្ថាបនារបស់ប្រទេសចិន ក្នុងការសម្របសម្រួលកិច្ចសន្ទនារវាងកម្ពុជា និងថៃ ដើម្បីដោះស្រាយស្ថានការណ៍ព្រំដែនដោយសន្តិវិធី។ **សម្តេចធិបតីនាយករដ្ឋមន្ត្រី**បានគូសបញ្ជាក់ថា ការគាំទ្រឥតងាករេរបស់ប្រទេសចិនសម្រាប់ការអនុវត្តពេញលេញនៃកិច្ចព្រមព្រៀងបទឈប់បាញ់ យន្តការត្រួតពិនិត្យរបស់អាស៊ានដែលដឹកនាំដោយប្រទេសម៉ាឡេស៊ី និងការបង្កើតក្រុមអ្នកសង្កេតការណ៍អាស៊ានដំបូង (AOT) គឺមិនអាចខ្វះបានក្នុងការស្តារសន្តិភាព ស្ថិរភាព និងប្រក្រតីភាពនៅតាមព្រំដែន។ **សម្តេចធិបតីនាយករដ្ឋមន្ត្រី**ក៏បានថ្លែងអំណរគុណចំពោះ**ឯកឧត្តមប្រធានាធិបតី** សម្រាប់ជំនួយមនុស្សធម៌ដ៏សប្បុរស ដែលមានសារៈសំខាន់ក្នុងការកសាងឡើងវិញនូវសហគមន៍ដែលរងការខូចខាតដោយសារជម្លោះប្រដាប់អាវុធ និងសម្រាលទុក្ខលំបាកដែលប្រជាពលរដ្ឋនៅតំបន់រងផលប៉ះពាល់បានប្រឈម។

ជាទីបញ្ចប់ ថ្នាក់ដឹកនាំទាំងពីរបានបញ្ជាក់សារជាថ្មីពីការប្តេជ្ញាចិត្តយ៉ាងមុតមាំ ក្នុងការលើកកម្ពស់ទំនាក់ទំនងកម្ពុជា-ចិនឱ្យកាន់តែមានកម្រិតខ្ពស់បន្ថែមទៀត។ ថ្នាក់ដឹកនាំទាំងពីរក៏បានសន្យាបន្តធ្វើការយ៉ាងជិតស្និទ្ធ ដើម្បីធានាភាពជាដៃគូឱ្យទទួលបានផលប្រយោជន៍ជាក់ស្តែង សម្រាប់ប្រជាជនទាំងពីរ និងរួមចំណែកយ៉ាងសំខាន់ដល់សន្តិភាព ស្ថិរភាព និងការអភិវឌ្ឍក្នុងតំបន់ និងពិភពលោក។

ថ្ងៃសៅរ៍ ៧កើត ខែភទ្របទ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែសីហា ឆ្នាំ២០២៥